# សេវាចែកអាហារចាប់ផ្តើមថ្ងៃទី១ ខែកញ្ញា

សឹងតែគ្រប់សាលារៀនទាំងអស់ក្នុងក្រសួងអប់រំឡុងប៊ីចនឹងមានចែកកញ្ចប់អាហារពេលព្រឹកនិងថ្ងៃត្រង់ពីថ្ងៃច័ន្ទដល់សុក្រចាប់ពី ថ្ងៃទី១ខែកញ្ញាទៅ។

មានសាលារៀនចំនួន 5 ដែលពុំមានចែកអាហារ សាលាទាំងនោះគឺសាលាបឋមសិក្សា Cubberley, Fremont , Longfellow និង Stevenson ព្រមទាំងសាលា California Academy of Mathematics and Science ផងដែរ។ សិស្សរបស់

ក្រសួងអប់រំឡុងប៊ីចអាចទៅយកកញ្ចប់អាហារនៅសាលាណាមួយក៏បាន។

តារាងវេលាចែកអាហារពីថ្ងៃទី១ដល់ទី១១កញ្ញាៈ

- ១១ព្រឹក ដល់ ១២:៣០ថ្ងៃ នៅសាលាបឋមសិក្សា សាលាអនុវិទ្យាល័យ សាលា K-8 និងសាលាវិទ្យាល័យ(លើកលែងតែសាលាវិទ្យាល័យ Jordan)
- ១២ថ្ងៃត្រង់ ដល់ ១:៣០ថ្ងៃ នៅសាលាវិទ្យាល័យ Jordan

តារាងវេលាចែកអាហារពីថ្ងៃ១៤កញ្ញាៈ

- ១១ព្រឹក ដល់ ១២:៣០ថ្ងៃ នៅសាលាបឋមសិក្សា និងសាលាវិទ្យាល័យ (លើកលែងតែសាលាវិទ្យាល័យ Jordan)
- ១២ថ្ងៃត្រង់ ដល់ ១:៣០ថ្ងៃ សាលាអនុវិទ្យាល័យ សាលា K-8 និងសាលាវិទ្យាល័យ Jordan

សាលា Avalon ថ្នាក់មត្តេយ្យ-១២ ដែលស្ថិតនៅលើកោះកាតាលីណានឹងមានចែកអាហារចាប់ពីថ្ងៃទី១កញ្ញា ិម៉ោង១១ព្រឹក-១ថ្ងៃ។

សិស្សឬមាតាបិតាអាចមកយកកញ្ចប់អាហារសម្រាប់សិស្សដែលមានចុះឈ្មោះរៀននៅក្នុងក្រសួងអប់រំ LBUSD ដែលរស់នៅក្នុងផ្ទះជាមួយគ្នាបាន។ សាលារៀនពុំអាចចែកអាហារដល់កុមារដែលពុំមានចុះឈ្មោះរៀនឬមិនទាន់ចូលរៀនបានទេ។

នៅពេលមកយកអាហារ មាតាបិតាឬសិស្សនឹងចាំបាច់ត្រូវប្រើលេខសម្ងាត់ PIN number បណ្ណអត្តសញ្ញាណពីឆ្នាំមុន ឬលេខ អត្តសញ្ញាណសិស្ស ដើម្បីបញ្ជាក់ថាមានចុះឈ្មោះរៀនក្នុងក្រសួងអប់រំឡុងប៊ីច។ គ្រួសារសិស្សអាចយកក្រដាសព្រិនចម្លងចេញមកពី ParentVue ដែលមានកាលវិភាគរៀនរបស់កូន ឬសំបុត្របញ្ជាក់ភាពមានសិទ្ធដែលផ្ញើរទៅឱ្យពីការិយាល័យផ្តល់សេវាកម្មអាហារ Nutrition Services ។ សិស្សដែលពុំមានសិទ្ធបានទទួលអាហារដោយទទេឬដោយចុះថ្លៃអាចទិញអាហារសាលាបាន។ តម្លៃអាហារសម្រាប់ឆ្នាំសិក្សាថ្មីមានចុះផ្សាយនៅក្នុងគេហទំព័រ Nutrition Services (ហើយក៏មាននៅក្នុងគេហទំព័រក្រសួងអប់រំ lbschools.net នៅក្នុងតារាងលេខរៀងអក្សរ A-Z )។ គ្រួសារទាំងអស់នឹងត្រូវគោរពតាមពិធីការនៅឆ្ងាយពីគ្នានៅពេលមកយកអាហារ ហើយត្រូវពាក់ម៉ាសផងដែរ។

សូមកុំភ្លេចចូលទៅគេហទំព័រ Nutrition Services ដើម្បីបំពេញពាក្យសុំតាមអនឡាញសម្រាប់ទទួលអាហារដោយទទេឬដោយចុះថ្លៃមុននឹងឆ្នាំសិក្សាថ្មីចាប់ផ្តើម។ បំពេញពាក្យសុំតាមអនឡាញមានភាពងាយស្រួលនិងរហ័ស។ យើងសូមអញ្ជើញក្រុមគ្រួសារឱយតាមដាន Nutrition Services តាមរយៈ Instagram នៅ @lbusdnutrition ។